ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៦២ សជណ.ទខ

# សេចក្តីជូនដំណឹង
## ស្តីពី ស្ថានភាពអាកាសធាតុ

បន្ទាប់ពីបានធ្វើការតាមដាន និងព្យាករណ៍លើស្ថានភាពអាកាសធាតុរួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា ៖ បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងទទួលឥទ្ធិពលខ្យល់មូសុងនិរតីខ្លាំង ហើយចាប់ពីថ្ងៃទី 07 ដល់ថ្ងៃទី 10 ខែសីហា ឆ្នាំ 2015 ព្រះរាជាណាចក្រកម្ពុជា ក៏នឹងទទួលឥទ្ធិពលពីកន្ទុយព្យុះទី 13 ឈ្មោះ **ស៊ូដឺល័រ** (SOUDELOR) បន្ថែមទៀត ។

ស្ថានភាពបែបនេះ នឹងធ្វើឱ្យផ្ទៃមេឃនៅតំបន់ឆ្នេរនៃខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប និងនៅលើផ្ទៃសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា មានសភាពអាប់អួរ និងមានភ្លៀងពីបង្គួរទៅច្រើន ព្រមទាំងមានខ្យល់បក់បោកខ្លាំង ។ រលកសមុទ្រអាចមានកំពស់ពី 1,00 m ទៅ 2,50 m ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន **ពិសេសចំពោះបងប្អូនប្រជានេសាទ និងអ្នកទេសចរ គួរផ្អាកសកម្មភាពនេសាទ និងការធ្វើដំណើរកំសាន្តលើផ្ទៃសមុទ្រ ចាប់ពីថ្ងៃទី 07 ដល់ថ្ងៃទី 10 ខែសីហា ឆ្នាំ 2015** ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០១៥*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh